ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ០៥ ករបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

-ដោយឃើញថា : ពាក្យបណ្តឹងរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ១៦២/៩៨ ន.ត.ក. ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្តីសំរេចបដិសេធ លេខ០៨-១៧១២/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្តឹង លេខ ០៣៨/៩៨ នតក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ប្តឹងគណៈកម្មការឃុំរៀបចំការបោះឆ្នោត ឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មិនគោរពជំហរអព្យាក្រឹតក្នុងពេលដំណើរការបោះឆ្នោត ជាពិសេសនៅពេលរាប់សន្លឹកឆ្នោត ជាបណ្តឹងមិនត្រឹមត្រូវ ។

-ដោយឃើញថា : ការចុះអង្កេតដល់កន្លែងកើតហេតុរបស់ក្រុមទី១ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានបញ្ជាក់ថា សាក្សីជាច្រើននាក់បានឃើញផ្ទាល់ភ្នែក ភ្នាក់ងារអង្កេតម្នាក់ ក្នុងមួយគណបក្ស បានចូលសង្កេតការណ៍ ការរាប់សន្លឹកឆ្នោត ក្រោយពីការសំរួលរបស់ប្រធានគណៈកម្មការឃុំ រៀបចំការបោះឆ្នោត ឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

-ដោយឃើញថា : មណ្ឌលរាប់សន្លឹកឆ្នោត ដែលជាបន្ទប់ថ្នាក់រៀន មិនមានលទ្ធភាពអោយភ្នាក់ងារច្រើននាក់ក្នុងមួយគណបក្ស ចូលសង្កេតបានទេ ។

-ដោយឃើញថា : ពាក្យបណ្តឹងនេះគ្មានទឡ្ហីករណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា ១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សំរេចបដិសេធពុំទទួលពាក្យបណ្តឹងនេះ ។

-ដោយឃើញថា : សេចក្តីសំរេចលេខ ០៨-១៧១២/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវ ។

### សំរេច

១-បដិសេធបណ្តឹងជំទាស់របស់គណបក្សហ្វ៊ុនស៊ិនប៉ិច លេខ ១៦២/៩៨ នតក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ទាក់ទងនឹងសេចក្តីសំរេច បដិសេធ លេខ ០៨ - ១៧១២/៩៨ គជប ចុះថ្ងៃ ទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្តឹងលេខ ០៣៨/៩៨ នតក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ប្តឹងគណៈកម្មការឃុំ រៀបចំការបោះឆ្នោត ឃុំចំបក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង មិនគោរពជំហរអព្យាក្រឹតក្នុងពេលដំណើរការបោះឆ្នោត ពិសេសក្នុងពេលរាប់សន្លឹកឆ្នោត ។

២-តម្កល់សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត លេខ ០៩-១៧១២/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដោយការបន្ថែមមូលហេតុមានសាក្សី បញ្ជាក់ថា ប្រធានគណៈកម្មការឃុំ រៀបចំការបោះឆ្នោត ប៉ុំចំរោក បានអនុញ្ញាតអោយភ្នាក់ងារសង្កេតការណ៍ម្នាក់ ក្នុងអ្នកគណបក្ស បានចូលសង្កេតការរាប់សន្លឹកឆ្នោត ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
**ចាន់ សុខ**

ជាការត្រឹមត្រូវតាមច្បាប់ដើម
លេខាកត់ត្រា
**ម៉េង គីមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ០៦ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

***

-ឃើញថា : ពាក្យបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច លេខ ១៦២/៩៨ ន.ត.ក. ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ជំទាស់នឹងសេចក្តីសំរេចបដិសេធរបស់គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត លេខ០៩-១៦១១/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធ ពាក្យបណ្តឹង លេខ ០៣៦/៩៨ នតក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្ស ហ៊្វុនស៊ិនប៉ិច ប្តឹងពីគណៈកម្មការ ឃុំ រៀបចំការបោះឆ្នោត ទូទាំងខេត្តស្វាយរៀង ថាមិនគោរពនីតិវិធី នៃការប្តឹងតវ៉ា និងថាគ្មានភាពប្រក្រតី នៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ជាបណ្តឹងគ្មានមូល ដ្ឋានច្បាស់លាស់ ។

-ឃើញថា : គណៈកម្មការឃុំរៀបចំការបោះឆ្នោត នៅក្នុងខេត្តស្វាយរៀង ពុំបានផ្តល់អាទិភាពអោយគណបក្សណាមួយឡើយ ក្នុងការសង្កេតការណ៍បោះឆ្នោត ក៏ដូចជាការរាប់សន្លឹកឆ្នោត ។

-ឃើញថា : នៅថ្នាក់គណៈកម្មការឃុំរៀបចំការបោះឆ្នោត ពុំមានបណ្តឹងតវ៉ា ពីភ្នាក់ងារសង្កេតការណ៍របស់គណបក្សពិសេស ភ្នាក់ងារសង្កេតការរបស់គណបក្សហ៊្វុនស៊ិនប៉ិចទេ ។

-ឃើញថា : ពាក្យបណ្តឹងនេះគ្មានទន្និករណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការ តាមមាត្រា ១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញ សំរេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។